**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

# បេសកកម្មលើកទីបី របស់លោក យ៉ាសហ៊ ហ្គាយ តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

ថ្ងៃទី ២៩ - ៣១ ខែ ឧសភា ឆ្នាំ ២០០៧

*ភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៧* - លោក **យ៉ាសហ៊ ហ្គាយ** តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា នឹងបំពេញទស្សនកិច្ចផ្លូវការលើកទីបីរបស់លោកមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី ២៩ ដល់ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០៧ ។ គោលបំណងសំខាន់នៃដំណើរទស្សនកិច្ចរបស់លោក គឺដើម្បីធ្វើការស្វែងយល់អំពីការវិវត្តន៍ថ្មីៗបំផុតនៅក្នុងកម្ពុជា ដើម្បីរៀបចំដាក់បង្ហាញរបាយការណ៍ប្រចាំឆ្នាំរបស់លោក ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ដែលគ្រោងធ្វើនៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០៧ នេះ ។

លោកតំណាងពិសេសសង្ឃឹមថា នឹងមានឱកាសធ្វើការពិភាក្សាអំពីរបាយការណ៍របស់លោកជាមួយតំណាងជាន់ខ្ពស់នានា នៃរាជរដ្ឋាភិបាលកម្ពុជា ។ កម្មវិធីនេះនឹងរួមបញ្ចូលផងដែរ នូវការជួបប្រជុំជាមួយតំណាងសង្គមស៊ីវិល គណបក្សនយោបាយ ទីភ្នាក់ងារសហប្រជាជាតិ និងសហគមន៍អ្នកការទូតនានា ។

សេចក្ដីថ្លែងការណ៍សារពត៌មានមួយ ដែលឆ្លុះបញ្ចាំងពីការសង្កេតសំខាន់ៗរបស់លោកតំណាងពិសេសអំពីបេសកកម្មរបស់លោក នឹងត្រូវចេញផ្សាយនៅខាងចុងនៃដំណើរទស្សនកិច្ចនេះ នៅថ្ងៃ ទី៣១ ខែឧសភា ឆ្នាំ២០០៧ ។